សាលាដំបូងខេត្តបាត់ដំបង
សំណុំរឿងព្រហ្មទណ្ឌ
លេខ៖១៥០៩/២៩-១២-២០
សំណុំរឿងជំនុំជម្រះ
លេខ៖ ២៧៦/១៨-០៥-២១
សាលក្រមព្រហ្មទណ្ឌ
លេខ៖៧៦៤"ក"/១៣-១០-២១

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តបាត់ដំបង

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តបាត់ដំបង នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ត្រូវនឹងថ្ងៃព្រហស្បតិ៍ ៩រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព-ស២៥៦៥ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ ត្រូវនឹងថ្ងៃពុធ ៧កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព-ស ២៥៦៥ ដែលមានសមាសភាពដូចតទៅ ៖

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ឯកឧត្តម [redacted] ប្រធានសាលាដំបូងខេត្តបាត់ដំបង

**ចៅក្រមប្រឹក្សា**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តបាត់ដំបង

លោក [redacted] ចៅក្រមសាលាដំបូងខេត្តបាត់ដំបង

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង
នៃអយ្យការអមសាលាដំបូងខេត្តបាត់ដំបង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តបាត់ដំបង

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៥០៩ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ ដែលមានជនជាប់ចោទ ៖

១-ឈ្មោះ [redacted] សារុំ ភេទប្រុស អាយុ៥៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅភូមិជីមាន់ ឃុំក្រែក ស្រុកពញាក្រែង ខេត្តកំពង់ចាម សាសនាព្រះពុទ្ធ មុខរបរ ធ្វើចំការ មានទីលំនៅបច្ចុប្បន្ន [redacted] ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន០៤ នាក់ ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] (ស្លាប់) កម្រិតវប្បធម៌ថ្នាក់ទី៤ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ (ក្នុងឃុំ)

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១២២២ ក-ព្រ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ ។



Scanned with CamScanner

២-ឈ្មោះ [redacted] សារ៉ាត ហៅ ហើម ឬ រម្យ ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅភូមិកូវ ឃុំព្រែក ស្រុកពញាព្រែក ខេត្តកំពង់ចាម សាសនាព្រះពុទ្ធ មុខរបរ ធ្វើស្រែ មានទី-លំនៅបច្ចុប្បន្នភូ[redacted] ខេត្តត្បូងឃ្មុំ ពោះម៉ាយ មានកូនចំនួន០១នាក់ ឪពុកឈ្មោះ [redacted] (រស់) ម្តាយឈ្មោះ [redacted] (រស់) កម្រិតវប្បធម៌ថ្នាក់ទី៥ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ (ក្នុងឃុំ)

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១២២១ ត-ព្រ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ ។

-ជាប់ចោទពីបទ " រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន " តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចមុខអនុវិទ្យាល័យសោហី ស្ថិតក្នុងក្រុមទី១២ ភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ ។

-លោក [redacted] ភារ៉ា អត្តលេខ ២០៤៨T ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ទូច សារុំ និងជនជាប់ចោទឈ្មោះ [redacted] សារ៉ាត ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៨១១ ជស-សព ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ។

-បានឃើញដីកាដំណោះស្រាយលេខ ២០៤ ដ-ជ-រ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបង ។

-បានឃើញដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ ២៥២៧ ត-ព្រ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តបាត់ដំបង ។

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ៖

កាលពីថ្ងៃ២៨ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង១៣និង៣០នាទី នៅចំណុចមុខអនុវិទ្យាល័យសោហី ស្ថិតនៅក្នុងក្រុមទី១២ ភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង កម្លាំងការិយាល័យប្រឆាំងគ្រឿងញៀន សហការនឹងកម្លាំងក្រុមអន្តរាគមន៍ប្រឆាំងបទល្មើស បានធ្វើការបង្ក្រាបករណីគ្រឿងញៀន ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] សារុំ ភេទប្រុស អាយុ ៥៩ឆ្នាំ បានទាក់ទងទិញគ្រឿងញៀនប្រភេទម៉ាទឹកកក ចំនួន០៥គីឡូក្រាម ពីជនមិនស្គាល់ឈ្មោះ ។ បន្ទាប់មកឈ្មោះ [redacted] សារុំ និងបក្ខពួកឈ្មោះ [redacted]ួយ ភេទប្រុស អាយុ៤៧ឆ្នាំ ឈ្មោះ [redacted] សារ៉ាត ភេទប្រុស អាយុ៣៥ឆ្នាំ បាននាំគ្នាជិះម៉ូតូយកថ្នាំញៀន ទៅលក់ឱ្យគេ រួចក៏ត្រូវសមត្ថ-កិច្ច ធ្វើការឃាត់ខ្លួន ដកហូតបានគ្រឿងញៀន និងបាននាំខ្លួនមកសាកសួរ តែម្តង ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] សារុំ វត្តមាន ជនជាប់ចោទឈ្មោះ [redacted] សារ៉ាត វត្តមាន និងលោក [redacted] ភារ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ វត្តមាន ។



Scanned with CamScanner

-ជនជាប់ចោទឈ្មោះ [redacted] សារុំ បានឆ្លើយថា ៖ ខ្លួនមិនធ្លាប់ជាប់ពន្ធនាគារទេ ។ សមត្ថកិច្ចបានដកហូតថ្នាំញៀន ពីខ្លួន គឺឈ្មោះ ខូវ ជាអ្នកផ្ញើឱ្យខ្លួនយកឱ្យគេនៅក្បែរស្ពានថ្ម ។ ឈ្មោះ ខូវ បានផ្ញើថ្នាំញៀនឱ្យខ្លួន តែខ្លួនមិនដឹងថាជាថ្នាំញៀនទេ គឺវាឱ្យខ្លួនយកទៅឱ្យគេ ។ ខ្លួនបានយកថ្នាំញៀន ឱ្យគេ ដោយមិនដឹងថាជាថ្នាំញៀន ឡើយ ។ ឈ្មោះ [redacted] សារ៉ាត ពុំបានដឹងរឿងអ្វីទេ គឺគាត់មកគ្រាន់បានជាគ្នា ។

-ជនជាប់ចោទឈ្មោះ [redacted] សារ៉ាត បានឆ្លើយថា ៖ ខ្លួនមិនដឹងរឿងអ្វីទាំងអស់ ។

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋាន ៖ ឆ្លងតាមការសួរដេញដោលនាពេលសវនាការ ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សារុំ និងឈ្មោះ [redacted] សារ៉ាត បានឆ្លើយដោះសារថា ពួកខ្លួន មិនដឹងថាអីវ៉ាន់ ដែលពួកខ្លួនបានទទួលដើម្បីយកទៅឱ្យគេបន្ត ជាថ្នាំញៀន នោះ គឺគ្រាន់តែជាការឆ្លើយដោះសារដើម្បីឱ្យបានរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ តែប៉ុណ្ណោះ ។ ជនជាប់ចោទទាំងពីរធ្លាប់បានឆ្លើយសារភាពនៅតំណាក់កាលសមត្ថកិច្ច នៅតំណាក់កាលអយ្យការ និងនៅតំណាក់កាលចៅក្រមស៊ើបសួរ រួចមកហើយថា ពួកខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ មែន ។ ដូច្នេះ តំណាងអយ្យការស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះ ផ្ដន្ទាទោសជនជាប់ចោទតាមផ្លូវច្បាប់ ។

-លោកមេធាវី [redacted] ភារ៉ា បានធ្វើសេចក្ដីសន្និដ្ឋាន ៖ ឆ្លងតាមការសួរដេញដោលនាពេលសវនាការ រួចមក ឃើញថា កូនក្ដីរបស់ខ្លួនទាំងពីរពិតជាធ្លាប់បានឆ្លើយសារភាពទទួលស្គាល់ពីកំហុសរបស់ខ្លួនរួចមកហើយ ។ ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទទាំងពីរនាក់ខ្លួនស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះ បន្ធូរបន្ថយទោសដល់ជនជាប់ចោទទាំងពីរ ។

ជនជាប់ចោទឈ្មោះ [redacted] សារុំ បាននិយាយសំដីចុងក្រោយថា ៖ ខ្លួនសំណូមពរ សុំឱ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួន ។

-ជនជាប់ចោទឈ្មោះ [redacted] សារ៉ាត បាននិយាយសំដីចុងក្រោយថា ៖ ខ្លួនសំណូមពរសុំឱ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួន ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវី

-ក្រោយពីបានស្ដាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារភស្ដុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>យល់ឃើញថា</u>

-កាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង១៣និង៣០នាទី ស្ថិតនៅចំណុចមុខវិទ្យាល័យ សោហ៊ីន ស្ថិតក្នុងក្រុមទី១២ ភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង មានករណី "រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន" មួយបានកើតឡើង ដែលសមត្ថកិច្ចឃាត់ខ្លួនបានជនជាប់ចោទចំនួន២នាក់ គឺឈ្មោះ ទូច សារុំ ភេទប្រុស អាយុ



Scanned with CamScanner

៥៩ឆ្នាំ និងឈ្មោះ [redacted] សារ៉ាត ភេទប្រុស អាយុ៣៥ឆ្នាំ និងបានដកហូតថ្នាំញៀនដូចមានក្នុងកំណត់ហេតុវត្ថុតាងចាប់យក ពិតប្រាកដមែន ។

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សារុំ នៅដំណាក់សមត្ថកិច្ច ដំណាក់កាលអយ្យការ និងនៅដំណាក់កាលចៅក្រមស៊ើបសួរ បានសារភាពថា ៖ ពិតជាបានយកថ្នាំញៀនមកលក់ឱ្យគេ ជាមួយក្មួយឈ្មោះ [redacted] សារ៉ាត ហៅ ហើម នៅខេត្តបាត់ដំបង ក្បែរមាត់ស្ទឹងសង្កែ ប្រាកដមែន ។ ចំពោះថ្នាំញៀនដែលសមត្ថកិច្ចចាប់យកមកនេះ ជារបស់ខ្លួន ដែលខ្លួនយកមកលក់ឱ្យគេ នៅថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០២០ នៅខេត្តបាត់ដំបង ។ ថ្នាំញៀនដែលខ្លួនយកមកលក់ឱ្យគេនេះ ក្នុង១គីឡូក្រាម តំលៃ១៣០០០ដុល្លារ ដោយក្នុង១គីឡូក្រាម ខ្លួនចំណេញបានប្រាក់៣០០០ដុល្លារ ។ មុនដំបូងមានគេ មកកម៉ង់ទិញថ្នាំញៀន ចំនួន៥គីឡូក្រាម ពេលនោះខ្លួនបានទំនាក់ទំនង ទៅម្ចាស់ថ្នាំញៀន សុំទិញថ្នាំញៀន ពីគេ ក្នុង១គីឡូក្រាម តំលៃ១០០០០ដុល្លារ ។ លុះនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ២០២០ ខ្លួនបានទំនាក់ទំនងជាមួយអ្នកកម៉ង់ថ្នាំញៀន ពីខ្លួន ចំនួន៥គីឡូក្រាម ក៏បានណាត់គ្នាទៅទូរទាត់ នៅខេត្តបាត់ដំបង ពេលនោះខ្លួនបានទៅពឹងក្មួយឈ្មោះ [redacted] សារ៉ាត និងឈ្មោះ ហួយ ឱ្យជួយជូនខ្លួនទៅខេត្តបាត់ដំបង ដើម្បីជួបមិត្តភក្តិ ។ ពេលមកដល់ខេត្តបាត់ដំបង ខ្លួនបានទំលាក់ឈ្មោះ ហួយ នៅផ្លូវកែងមួយ ហើយខ្លួន និងក្មួយ បានជិះម៉ូតូ ទៅជួបម្ចាស់ថ្នាំញៀន ដោយដាក់នឹងការ៉ុង រួចខ្លួនក៏ជិះម៉ូតូចេញ មកលក់ថ្នាំញៀន ឱ្យគេចំនួន៥គីឡូក្រាមក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនខ្លួន និងក្មួយ រួមជាមួយថ្នាំញៀន ៥គីឡូក្រាម ។

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សារ៉ាត នៅដំណាក់សមត្ថកិច្ច ដំណាក់កាលអយ្យការ និងនៅដំណាក់កាលចៅក្រមស៊ើបសួរ បានសារភាពថា ៖ ខ្លួនពិតជាបានជូនមា របស់ខ្លួន ឈ្មោះ [redacted] សារុំ ទៅលក់ថ្នាំញៀនចំនួន៥គីឡូក្រាម មែន ។ មុនដំបូងនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ មាខ្លួនឈ្មោះ [redacted] សារុំ បានពឹងខ្លួន ឱ្យជូនមកខេត្តបាត់ដំបង និងឈ្មោះ ហួយ ។ ពេលមកដល់ខេត្តបាត់ដំបង មារបស់ខ្លួនបានទំលាក់ បងហួយ ចុះនៅផ្លូវកែងមួយ បណ្ដោយផ្លូវជាតិលេខ៥ រីឯគាត់ និងខ្លួនបានជិះម៉ូតូបន្តឆ្ងាយបន្តិច មារបស់ខ្លួនបានទៅជួបមនុស្សម្នាក់ មិនស្គាល់ឈ្មោះ ហើយយកការ៉ុងពីគេ រួចក៏ជិះម៉ូតូចូលក្រុង តាមមាត់ស្ទឹងសង្កែ ក៏ត្រូវសមត្ថកិច្ច ឃាត់ពួកខ្លួន ហើយបន្តទៅចាប់បងហួយ ទៀត រួចក៏បញ្ជូនពួកខ្លួនមកកាន់ស្នងការដ្ឋាននគរបាល ខេត្តបាត់ដំបង តែម្តង ។

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សារុំ ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សារ៉ាត អាចកំណត់បានថា ៖ ជនជាប់ចោទឈ្មោះ [redacted] សារុំ ជនជាប់ចោទឈ្មោះ [redacted] សារ៉ាត ពិតជាបានប្រព្រឹត្តអំពើ " រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន " តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចមុខអនុវិទ្យាល័យ សោហ៊ី ស្ថិតក្នុងក្រុមទី១២ ភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ ប្រាកដមែន ។

-តាមកំណត់ហេតុទទួលវត្ថុតាង លេខ ៦៤៤ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តបាត់ដំបង ឃើញមាន ៖



Scanned with CamScanner

១-ថ្នាំញៀនប្រកក្នុងស្រោមសំបុត្រពណ៌គគីរបិតជិត ក្នុងកេះដែក ចំនួន០៣ កេះ ។

២-ទូរស័ព្ទដៃចាស់ចំនួន១គ្រឿង (ចាស់ខូច) ។

-តាមកំណត់ហេតុ រាប់ ថ្លឹង និងដកសំណាកគ្រឿងញៀន ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ ឃើញមាន ៖ ថ្នាំញៀនប្រភេទ **មេតំហ្វេតាមីន** (ហៅក្រៅម៉ាទឹកកកឬ អាយ)៖

១-កញ្ចប់ធំទី១ ទម្ងន់១០១១.៨៥ក្រាម (ថ្លឹងទាំងសំបក) សំបកទម្ងន់១៤.៨៣ក្រាម មានសាច់ថ្នាំសុទ្ធ ទម្ងន់៩៩៧.០២ក្រាម បានដកសំណាកចំនួន០២កញ្ចប់ ៖

១-១-កញ្ចប់ទី១ ទម្ងន់៦.២៨ក្រាម (ដោយមិនគិតទម្ងន់នៃសំបក)

១-២-កញ្ចប់ទី២ ទម្ងន់៥.១៥ក្រាម(ដោយមិនគិតទម្ងន់នៃសំបក)

**នៅសល់ក្នុងសំណុំរឿង ទម្ងន់៩៨៥.៥៩ក្រាម(ដោយមិនគិតពីទម្ងន់នៃសំបក)**

២-កញ្ចប់ធំទី២ ទម្ងន់១០១១.៦០ក្រាម(ថ្លឹងទាំងសំបក) សំបកទម្ងន់១៤.៨៣ក្រាម មានសាច់ថ្នាំសុទ្ធ ទម្ងន់៩៩៦.៨៦ក្រាម បានដកសំណាកចំនួន០២កញ្ចប់ ៖

២-១-កញ្ចប់ទី១ ទម្ងន់៧.៥៦ក្រាម (ដោយមិនគិតទម្ងន់នៃសំបក)

២-២-កញ្ចប់ទី២ ទម្ងន់៦.០៣ក្រាម(ដោយមិនគិតទម្ងន់នៃសំបក)

**នៅសល់ក្នុងសំណុំរឿង ទម្ងន់៩៨៣.២៧ក្រាម(ដោយមិនគិតពីទម្ងន់នៃសំបក)**

៣-កញ្ចប់ធំទី៣ ទម្ងន់១០១១.៨៨ក្រាម(ថ្លឹងទាំងសំបក) សំបកទម្ងន់១៤.៨៣ក្រាម មានសាច់ថ្នាំសុទ្ធ ទម្ងន់៩៩៧ក្រាម បានដកសំណាកចំនួន០២កញ្ចប់ ៖

៣-១-កញ្ចប់ទី១ ទម្ងន់៧.៤៤ក្រាម (ដោយមិនគិតទម្ងន់នៃសំបក)

៣-២-កញ្ចប់ទី២ ទម្ងន់៦.៤៣ក្រាម(ដោយមិនគិតទម្ងន់នៃសំបក)

**នៅសល់ក្នុងសំណុំរឿង ទម្ងន់៩៤០.៥៦ក្រាម(ដោយមិនគិតពីទម្ងន់នៃសំបក)**

៤-កញ្ចប់ធំទី៤ ទម្ងន់១០១១.៦៦ក្រាម(ថ្លឹងទាំងសំបក) សំបកទម្ងន់១៤.៨៣ក្រាម មានសាច់ថ្នាំសុទ្ធ ទម្ងន់៩៩៦.៨២ក្រាម បានដកសំណាកចំនួន០២កញ្ចប់ ៖

៤-១-កញ្ចប់ទី១ ទម្ងន់៧.៧៥ក្រាម (ដោយមិនគិតទម្ងន់នៃសំបក)

៤-២-កញ្ចប់ទី២ ទម្ងន់៦.៦៦ក្រាម(ដោយមិនគិតទម្ងន់នៃសំបក)

**នៅសល់ក្នុងសំណុំរឿង ទម្ងន់៩៨២.៤១ក្រាម(ដោយមិនគិតពីទម្ងន់នៃសំបក)**

៥-កញ្ចប់ធំទី៥ ទម្ងន់១០១១.៨២ក្រាម (ថ្លឹងទាំងសំបក) សំបកទម្ងន់១៤.៨៣ក្រាម មានសាច់ថ្នាំសុទ្ធ ទម្ងន់៩៩៦.៧៨ក្រាម បានដកសំណាកចំនួន០២កញ្ចប់ ៖

៥-១-កញ្ចប់ទី១ ទម្ងន់៩.៨៣ក្រាម (ដោយមិនគិតទម្ងន់នៃសំបក)

៥-២-កញ្ចប់ទី២ ទម្ងន់៨.៤១ក្រាម(ដោយមិនគិតទម្ងន់នៃសំបក)

**នៅសល់ក្នុងសំណុំរឿង ទម្ងន់៩៧៨.៥៤ក្រាម(ដោយមិនគិតពីទម្ងន់នៃសំបក)** ជារបស់ជនជាប់ចោទឈ្មោះ[redacted]សារ៉ុ និងជនជាប់ចោទឈ្មោះ[redacted]សារ៉ាត ។

-តាមលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ ៣០១៩៤/២១ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបញ្ជាក់ថា ៖ គ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ **មេតំហ្វេតាមីន** (ហៅក្រៅម៉ាទឹកកក ឬ អាយ) ដែលមានកម្រិតភាព



Scanned with CamScanner

សុទ្ធ ៧៣.០៧% វាស្ថិតក្នុង តារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុង តារាងឧបសម្ព័ន្ធ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-ថ្នាំញៀនដែលបានដកហូតពីជនជាប់ចោទឈ្មោះ [redacted] សារុំ និងជនជាប់ចោទឈ្មោះ [redacted] សារ៉ាត ជាប្រភេទ មេតំហ្វេតាមីន (ហៅក្រៅម៉ាទឹកកក) ទម្ងន់ ៤៩៨៤.៤៨ ក្រាម មានបរិមាណសារធាតុ មេតំហ្វេតាមីន ចំនួន ៧៣.០៧% ដូច្នេះ វាមានបរិមាណសុទ្ធ ចំនួន ៣៦៤២.១៥ក្រាម ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-អំពើរបស់ជនជាប់ចោទដែលបានលក់ និងទិញដើម្បីលក់គ្រឿងញៀនដោយគ្មានការអនុញ្ញាត ជាអំពើល្មើសច្បាប់ព្រហ្មទណ្ឌ ពីបទ " រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន " តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-អំពើរបស់ជនជាប់ចោទ ស្តែងចេញពីចេតនាទុច្ចរិត ដោយដឹងថា អំពើលក់គ្រឿងញៀនជាអំពើខុសច្បាប់ តែពួកខ្លួននៅតែប្រព្រឹត្ត ដោយមានចេតនាបំពានលើច្បាប់ ។

-ជនជាប់ចោទខាងលើ ជានីតិជន និងជាសមត្ថជនដែលអាចទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត ។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទ បានធ្វើឱ្យប៉ះពាល់របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម និងច្បាប់របស់រដ្ឋ ។

-មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើ ៖ ១-ឈ្មោះ [redacted] សារុំ ភេទប្រុស អាយុ៥៩ឆ្នាំ (មានសាវតារជាតិដូចខាងលើ) និង ២-ឈ្មោះ [redacted] សារ៉ាត ភេទប្រុស អាយុ៣៥ឆ្នាំ (មានសាវតារជាតិដូចខាងលើ) ពីបទ " រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន " តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចមុខអនុវិទ្យាល័យសោហី ស្ថិតក្នុងក្រុមទី១២ ភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ ។

-ចំពោះវត្ថុតាង ដូចក្នុងកំណត់ហេតុទទួលវត្ថុតាង លេខ ៦៤៤ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តបាត់ដំបង តុលាការនឹងសម្រេចរឹបអូស តាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ ។

## **<u>ហេតុដូច្នេះសម្រេច</u>**

១-ផ្តន្ទាទោសដាក់ពន្ធនាគារលើ ៖

១-១-ឈ្មោះ [redacted] សារុំ ភេទប្រុស អាយុ៥៩ឆ្នាំ (មានសាវតារជាតិដូចខាងលើ)

១-២-ឈ្មោះ [redacted] សារ៉ាត ភេទប្រុស អាយុ៣៥ឆ្នាំ (មានសាវតារជាតិដូចខាងលើ)

ក្នុងម្នាក់ៗកំណត់រយៈពេល ២០ឆ្នាំ(ម្ភៃឆ្នាំ) គិតចាប់ពីថ្ងៃឃុំខ្លួនបណ្តោះអាសន្ន និងពិន័យជាប្រាក់ ក្នុងម្នាក់ៗចំនួន ៨០,០០០,០០០រៀល(ប៉ែតសិបលានរៀល) បង់ចូលជាថវិការដ្ឋ ពីបទ " រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន " តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់



Scanned with CamScanner

ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចមុខអនុវិទ្យាល័យ សោហី ស្ថិតក្នុងក្រុមទី១២ ភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ២០២០ ។

២-វត្ថុតាង(ដូចក្នុងកំណត់ហេតុទទួលវត្ថុតាង លេខ ៦៤៤ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តបាត់ដំបង) រួមមាន ៖

២-១-ថ្នាំញៀនក្រាមម្សៅប្រភេទ មេតំហ្វេតាមីន (ហៅក្រៅម៉ាទឹកកក ឬ អាយ) ទម្ងន់ ៤៨៧០.៣៧ក្រាម ត្រូវរឹបអូសយកទៅបំផ្លាញចោល ។

២-២-ទូរស័ព្ទដៃ០១គ្រឿង ត្រូវរឹបអូសចូលជាសម្បត្តិរដ្ឋ ។

-សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ត្រូវនឹងថ្ងៃព្រហស្បតិ៍ ៩រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ ត្រូវនឹងថ្ងៃពុធ ៧កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥ ចំពោះមុខជនជាប់ចោទ ឈ្មោះ[redacted]សារុំ និងជនជាប់ចោទឈ្មោះ[redacted]សារ៉ាត ។

-ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍ តាមកាលកំណត់នៃច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] |